## ឯកសារស្រាវជ្រាវសង្ខេប

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

# ការរួមចំណែករបស់សភានៅក្នុងសន្និសីទអង្គការ សហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៥


អ្នកទទួលបន្ទុកស្រាវជ្រាវៈ លោក ឆន ប៉ូល

ជំនួយការស្រាវជ្រាវៈ លោក នន់ អស្សាច័ន្ទ



ខែកញ្ញា ២០១៥

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់ សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបសសមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាងឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយហើយ ក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះ ស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៥ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា

ប្រវត្តិ ........ 4

សន្និសីទអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៥ ........ 5

  កិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៥........ 6

  បញ្ហាដែលទាក់ទិននឹងអត្ថប្រយោជន៍របស់កម្ពុជា........ 7

មុខងាររបស់សភា និងការប្រែប្រួលអាកាសធាតុ........ 13

សហភាពអន្តរសភា និងការប្រែប្រួលអាកាសធាតុ ........ 13

អាស៊ាន និងការប្រែប្រួលអាកាសធាតុ........ 15

សកម្មភាពកម្ពុជាឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ........ 17

ឯកសារយោង ........ 21

## ប្រវត្តិ

អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (United Nations Framework Convention on Climate Change: UNFCCC) គឺជាកិច្ចព្រមព្រៀងអន្តរជាតិដំបូង ទទួលស្គាល់ និងដែលបង្កើតឡើងដើម្បីដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុ ដែលមនុស្សជាអ្នកបង្កឡើង។ អនុសញ្ញានេះចូលជាធរមាននៅថ្ងៃ ទី ២១ ខែ មីនា ឆ្នាំ១៩៩៤។ ប្រទេសចំនួន ១៩៥ ដែលបានផ្តល់សច្ចាប័នដល់អនុសញ្ញានេះហៅរដ្ឋភាគី។ កម្ពុជាផ្តល់សច្ចាប័នដល់អនុសញ្ញានេះនៅឆ្នាំ១៩៩៥ និងអនុសញ្ញានេះចូលជាធរមាននៅកម្ពុជានៅឆ្នាំ ១៩៩៦។[1]

ដោយមើលឃើញថាការប្រែប្រួលអាកាសធាតុគឺជាបញ្ហារួមមួយរបស់មនុស្សជាតិ អនុសញ្ញានេះ(UNFCCC) បានបង្កើតក្របខណ្ឌច្បាប់សម្រាប់ប្រទេសជាសមាជិកដើម្បីដោះស្រាយបញ្ហានៃការប្រែប្រួល អាកាសធាតុនេះ។[2] ដោយយោងទៅលើសន្ធិសញ្ញានេះ មានលក្ខខណ្ឌសំខាន់ចំនួនបីសម្រាប់ភាគីជាសមាជិក៖

១. ប្រមូល និងចែករំលែកព័ត៌មានទាក់ទងនឹងការបំភាយឧស្ម័នផ្ទះកញ្ចក់ (greenhouse gas emissions) គោលនយោបាយជាតិ និងគំរូអនុវត្តន៍ល្អៗ។

២. ដាក់ចេញនូវយុទ្ធសាស្ត្រជាតិសម្រាប់ឆ្លើយតបនឹងការបំភាយឧស្ម័នផ្ទះកញ្ចក់ (greenhouse gas emissions) និងការបន្សាំទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលអាចកើតមាន។

៣. សហការរៀបចំកម្មវិធីបន្សាំនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ

ជាងនេះទៅទៀត UNFCCC បានជំរុញឲ្យបណ្តាប្រទេសអភិវឌ្ឍន៍ជួយឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និងការកសាងសមត្ថភាពដល់ប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។[3]

គោលបំណងដ៏សំខាន់របស់ UNFCCC គឺការរក្សាឲ្យបាននូវស្ថេរភាពកំហាប់ឧស្ម័នផ្ទះកញ្ចក់ (greenhouse gas concentrations) ក្នុងកម្រិតមួយដែលនឹងការពារកុំឲ្យមានការប៉ះពាល់កាន់តែច្រើន

---

[1]UNFCCC website. Status of Ratification of the UNFCCC. Accessed on September 1, 2015 at: https://unfccc.int/essential_background/convention/status_of_ratification/items/2631txt.php

[2]The United Nations Framework Convention on Climate Change. See brief information on http://unfccc.int/essential_background/convention/items/2627.php

[3]UNFCCC website. First steps to a safer future: Introducing the United Nations Framework Convention on Climate Change. Accessed on September 1, 2015 at: http://unfccc.int/essential_background/convention/items/6036.php

ទៀតទៅលើអាកាសធាតុតាមរយៈសកម្មភាពរបស់មនុស្ស។ ទោះជាយ៉ាងនេះក្តី UNFCCC ពុំមានកំណត់គោលដៅ នៃការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់សម្រាប់រដ្ឋភាគីទេ។ ដើម្បីសម្រេចគោលដៅដ៏សំខាន់របស់ UNFCCC ពិធីសារក្យូតូ(Kyoto Protocol) ត្រូវបានអនុម័ត នៅប្រទេសជប៉ុន ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ១៩៩៧ និងចូលជាធរមាន ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៥។[4] កម្ពុជាផ្តល់សច្ចាប័នដល់ពិធីសារក្យូតូនេះនៅឆ្នាំ២០០២ ដែលចូលជាធរមាននៅឆ្នាំ២០០៥។[5] ពិធីសារក្យូតូនេះ តម្រូវឲ្យប្រទេសអភិវឌ្ឍន៍កាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់។ ពិធីសារនេះ ក៏តម្រូវឲ្យបង្កើតមូលនិធិបន្សាំ ដែលនឹងជួយឧបត្ថម្ភគាំទ្រថវិកាគម្រោងកម្មវិធីបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលជារដ្ឋភាគីរបស់ពិធីសារក្យូតូ ដើម្បីឲ្យរដ្ឋភាគីដែលជាប្រទេសកំពុងអភិវឌ្ឍន៍ទាំងនោះ អាចបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។[6]

## សន្និសីទអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៥

សន្និសីទអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុឆ្នាំ ២០១៥ ឬសម័យប្រជុំលើកទី ២១ នៃសន្និសីទរដ្ឋភាគីរបស់អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (United Nations Framework Convention on Climate Change: COP21/CMP11) ឬអាចហៅបានថា ប៉ារីសឆ្នាំ២០១៥ នឹងប្រារព្ធឡើងនៅ ទីក្រុងប៉ារីស ប្រទេសបារាំង ចាប់ពីថ្ងៃទី៣០ ខែ វិច្ឆិកា រហូតដល់ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ ២០១៥។ ប៉ារីសឆ្នាំ២០១៥ មានគោលដៅឈានទៅរកកិច្ចព្រមព្រៀងអន្តរជាតិថ្មីមួយស្តីពីការប្រែប្រួលអាកាសធាតុ ដែលនឹងអនុវត្តដោយគ្រប់រដ្ឋភាគី និងចូលជាធរមានចាប់ពីឆ្នាំ២០២០។[7] កិច្ចព្រមព្រៀងអន្តរជាតិថ្មីស្តីពីការប្រែប្រួលអាកាសធាតុនេះ ដែលនឹងជំនួសពិធីសារក្យូតូនឹងផុតកំណត់នៅឆ្នាំ២០២០ មានគោលដៅការរក្សាការកើនកម្តៅពិភពលោកឲ្យស្ថិតនៅក្រោម២អង្សាសេ។

---

[4] UNFCCC website. Kyoto Propocol. Accessed on September 1, 2015 at: http://unfccc.int/kyoto_protocol/items/2830.php
[5] UNFCCC website. Status of Ratification of the Kyoto Protocol. Accessed on September 1, 2015 at: http://unfccc.int/kyoto_protocol/status_of_ratification/items/2613.php
[6] UNFCCC website. Kyoto Protocol. Accessed on September 1, 2015 at: http://unfccc.int/kyoto_protocol/items/2830.php
[7] What is COP21/CMP11? Paris 2015. Accessed on August 25, 2015 at: http://www.cop21.gouv.fr/en/cop21-cmp11/what-cop21-cmp11

## កិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ ២០១៥

សេចក្តីព្រាងនៃកិច្ចព្រមព្រៀងដែលរៀបចំឡើងសំរាប់កិច្ចចរចារ មានវិធានការសំខាន់ៗចំនួនបីៈ (១) វិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ [8] (២)វិធានការបន្សាំ[9] និង (៣)វិធានការគាំទ្រ។ ទីមួយ វិធានការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ក្នុងរយៈពេលវែង មានគោលបំណងកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដើម្បីទប់ការកើនឡើងកម្តៅផែនដីឲ្យស្ថិតនៅក្រោម ២អង្សាសេ ដូចដែលបានបញ្ជាក់នៅក្នុងមាត្រា២ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (United Nations Framework Convention on Climate Change)។ ទីពីរ វិធានការបន្សាំក្នុងរយៈពេលវែងកាត់បន្ថយភាពងាយរងគ្រោះទៅនឹងផលប៉ះពាល់ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងជួយសហគមន៍ដែលប្រឈមនឹងផលប៉ះពាល់។ ទីបី កញ្ចប់កាគាំទ្ររួមមាន ហិរញ្ញវត្ថុ ការបង្កើនសមត្ថភាព និងការអភិវឌ្ឍន៍ និងការផ្ទេរបច្ចេកវិជ្ជាទៅប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីជួយឲ្យពួកគេអាចសម្រេចគោលដៅកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងបន្សាំរយៈពេលវែង។ វិធានការកាត់បន្ថយបំភាយឧស្ម័នផ្ទះកញ្ចក់ និងបន្សាំនឹងអនុវត្តដោយផ្អែកទៅលើគោលការណ៍ ការទទួលខុសត្រូវរួមគ្នាតែមានតួនាទីផ្សេងគ្នា និងទៅតាមស្ថានភាពរបស់រដ្ឋភាគីនីមួយៗ។[10]

មានសន្និសីទអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ចំនួន៤ គឺ នៅទីក្រុងឌឺបិន (Durban) ឆ្នាំ២០១១ ដូហា (Doha) ឆ្នាំ២០១២ វ៉ស (Warsaw) ឆ្នាំ២០១៣ និងលីម៉ា (Lima) ឆ្នាំ២០១៤ ដែលពាក់ព័ន្ធនឹងដំណើរការរៀបចំឲ្យមានកិច្ចព្រមព្រៀងអន្តរជាតិថ្មីនេះ។ សន្និសីទអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុឆ្នាំ២០១៥ រំពឹងថានឹងឈានទៅរកកិច្ចព្រមព្រៀងអន្តរជាតិថ្មី ស្តីពីការប្រែប្រួលអាកាសធាតុនេះ។

---

[8] វិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ជាអន្តរការគមន៍ទាំងឡាយណាដើម្បីកាត់បន្ថយ ការបំភាយឧស្ម័នផ្ទះកញ្ចក់ ក៏ដូចជាការរួមចំនែកជួយឲ្យបរិយាកាសកាន់តែស្អាត។

[9] និយមន័យពាក្យការបន្សាំត្រូវបានកំណត់ដោយក្រុមការងារអន្តររដ្ឋាភិបាលស្តីពីបម្រែបម្រួលអាកាសធាតុ (IPCC) គឺ "ជាការកែប្រែក្នុងធម្មជាតិ និងសកម្មភាពមនុស្សដើម្បីឆ្លើយតបនឹងភាពមិនប្រក្រតីនៃអាកាសធាតុ និងឥទ្ធិពលរបស់វាដែលអាចមានផលប៉ះពាល់ជាច្រើន"។ សក្តានុពលនៃការបន្សាំអាចធ្វើឲ្យកាត់បន្ថយផលប៉ះពាលអាក្រក់របស់បម្រែបម្រួលអាកាសធាតុ និងការបង្កើនអត្ថប្រយោជន៍ផ្សេងៗ ប៉ុន្តែពុំអាចរាំរាំងបានទាំងស្រុងឡើយ។

[10] ACT 2015. Getting Specific on the 2015 Climate Change Agreement: Suggestions for the Legal Text with Explanatory Memorandum. Accessed on August 21, 2015 at: http://www.wri.org/sites/default/files/uploads/ACT2015_LegalSuggestions.pdf

## បញ្ហាដែលទាក់ទិននឹងអត្ថប្រយោជន៍របស់កម្ពុជា

ផ្នែកខាងក្រោមនេះ ជាបញ្ហាដែលកម្ពុជាគួរចាប់អារម្មណ៍ ដែលត្រូវបានពិភាក្សានៅក្នុងកិច្ចចរចារនៅសន្និសីទអង្គការសហប្រជាជាតិពីការប្រែប្រួលអាកាសអាកាសធាតុឆ្នាំ២០១៤ នៅទីក្រុងលីម៉ាៈ

*១. ផែនការការចូលរួមចំណែកដែលកំណត់ដោយរដ្ឋភាគី (Intended Nationally Determined Contributions: INDCs)*

ការកំណត់គោលដៅ និងភាពជោគជ័យ នៃកិច្ចព្រមព្រៀងថ្មីនេះ គឺពឹងផ្អែកមួយផ្នែកធំលើ ផែនការការចូលរួមចំណែកដែលបានកំណត់ដោយរដ្ឋភាគី (INDCs)។ ត្រឹមថ្ងៃទី៣១ ខែមិនា ឆ្នាំ ២០១៥ រដ្ឋភាគីទាំងអស់ត្រូវផ្ញើផែនការការចូលរួមចំណែកដែលកំណត់ដោយរដ្ឋភាគី (INDCs) ដែលបង្ហាញអំពីការសន្យាកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់នៅឆ្នាំ ២០២៥ ដើម្បីរួមចំណែកក្នុងការសម្រេចគោលបំណង នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។

នៅសន្និសីទនៅទីក្រុងលីម៉ា គេពុំអាចឈានទៅរកការព្រមព្រៀងគ្នាថាតើផែនការការចូលរួមចំណែកដែលកំណត់ដោយរដ្ឋភាគី (INDCs) គួរតែនិយាយផ្តោតជាសំខាន់តែលើវិធានកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ឬក៏ទៅលើវិធានការបន្សាំ និងការសន្យារបស់ប្រទេសអភិវឌ្ឍន៍ចំពោះការផ្តល់ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសមកដល់ប្រទេសកំពុងអភិវឌ្ឍន៍។

មកដល់ពេលនេះ មានប្រទេសចំនួន ១១៩ ដែលបានដាក់ជូន អង្គការសហប្រជាជាតិ នូវផែនការការចូលរួមចំណែកដែលកំណត់ដោយរដ្ឋភាគី (INDCs)។ បន្ទាប់ពីពិនិត្យផែនការនេះ (INDCs) ពីប្រទេសអភិវឌ្ឍន៍ ពុំមានការសន្យារបស់ប្រទេសអភិវឌ្ឍន៍លើការផ្តល់ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសមកកាន់ប្រទេសកំពុងអភិវឌ្ឍន៍ឡើយ។

ប្រទេសកម្ពុជាបានផ្ញើផែនការការចូលរួមចំណែកដែលកំណត់ដោយរដ្ឋភាគី (INDC) នៅខែ កញ្ញា ឆ្នាំ ២០១៥។ បើផ្អែកទៅលើ INDC របស់កម្ពុជា ប្រទេសកម្ពុជា មានវិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ២៧% នៅឆ្នាំ ២០៣០ នឹង ពង្រីកគម្របព្រៃឈើឲ្យបាន ៦០%។ ទាក់ទងនឹងវិធានការបន្សាំវិញ ប្រទេសកម្ពុជានឹងកាត់បន្ថយភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការពង្រឹងសមត្ថភាពបន្សាំរបស់សហគមន៍ កែលម្អរប្រព័ន្ធផ្តល់ព្រមានជាមុន កែលម្អរហេដ្ឋារចនាសម្ព័ន្ធកសិកម្ម អនុវត្ត

បច្ចេកទេសកសិកម្មដែលធន់នឹងការប្រែប្រួលអាកាសធាតុ អនុវត្តកម្មវិធីដែលកាត់បន្ថយការប្រឈមនឹងជំងឺផ្សេងៗដែលបណ្តាលពីការប្រែប្រួលអាកាសធាតុ នឹងបង្កើនសមត្ថភាពបច្ចេកទេស និងស្ថាប័នដែលពាក់ព័ន្ធនឹងបញ្ហាការប្រែប្រួលអាកាសធាតុ។[11]

*២. ភាពខុសគ្នា*

ប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើនជម្រុញឲ្យមានការបែងចែកតួនាទីឲ្យច្បាស់លាស់ រវាងប្រទេសអភិវឌ្ឍន៍ និង ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងយុទ្ធនាការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (ឧ. គួរឲ្យមានការបែងចែកឲ្យច្បាស់អំពីតួនាទីរវាងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ)។ ក៏ប៉ុន្តែប្រទេសអភិវឌ្ឍន៍បានបដិសេធគោលជំហានេះ។ ប្រទេសចិន និងសហរដ្ឋអាមេរិចបានចេញសេចក្តីថ្លែងការណ៍ ដែលមានលក្ខណៈសម្របសម្រួលមួយ ដែលផ្តល់ពាក្យពេចន៍មួយចំនួនដែលប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍យកមកប្រើប្រាស់ដើម្បីសម្របសម្រួលគ្នា។ ពាក្យពេចន៍ទាំងនោះដកស្រង់ចេញពីគោលការណ៍របស់ UNFCCC ពោលគឺគោលការណ៍«ការទទួលខុសត្រូវរួមគ្នាតែមានតួនាទីផ្សេងគ្នា»(Common but differentiated responsibilities)[12] ទៅតាមសមត្ថភាព

---

[11] Royal Government of Cambodia 2015. Intended Nationally Determined Contributions submitted to the UNFCCC secretariat. Accessed on October 05, 2015 at: http://www4.unfccc.int/submissions/INDC/Published%20Documents/Cambodia/1/Cambodia's%20INDC%20to%20the%20UNFCCC.pdf

[12]ការទទួលខុសត្រូវរួមគ្នា តែមានតួនាទីផ្សេងគ្នា តាមសមត្ថភាពរដ្ឋភាគីនីមួយៗ៖ ដោយហេតុថាប្រទេសជាច្រើនមានកម្រិតសមត្ថភាពខុសគ្នាក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សន្ធិសីទតម្រូវឲ្យប្រទេសអភិវឌ្ឍន៍ធ្វើជាអ្នកដឹកនាំក្នុងកិច្ចប្រយុទ្ធប្រឆាំងនេះ និងដាក់បន្ទុកឲ្យប្រទេសទាំងនេះ ត្រូវកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងត្រូវគាំទ្រហិរញ្ញវត្ថុ ដែលជួលសម្រួលដល់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការអនុវត្តវិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងវិធានការបន្សាំ ។ អនុសញ្ញាក៏តម្រូវឲ្យមានការផ្ទេរបច្ចេកវិទ្យា និងចំនេះដឹងទៅឲ្យប្រទេសក្រីក្រ និងកំពុងអភិវឌ្ឍន៍ដែរ (សូមមើលនៅអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ)។ ក្នុងសេចក្តីប្រកាសរួមមួយរបស់ អាមេរិក ចិន បានប្រើឃ្លា "ការទទួលខុសត្រូវរួមគ្នាតែមានតួនាទីផ្សេងគ្នា ទៅតាមសមត្ថភាព និងទៅតាមស្ថានភាពរបស់រដ្ឋភាគីនីមួយៗ" ដែលបន្ថែម "ទៅតាមស្ថានភាពរបស់រដ្ឋភាគីនីមួយៗ" ។ ចំពោះឃ្លានេះមានការបកស្រាយថានៅស្ថានភាពរបស់រដ្ឋភាគីវិវឌ្ឍ តួនាទីរបស់រដ្ឋភាគីក៏គួមានការផ្លាស់ប្តូរដែរ។

(respective capabilities) និងគោលការណ៍«ទៅតាមស្ថានភាពរបស់រដ្ឋភាគីនីមួយៗ» (in light of difference national circumstances)។[13]

*៣. ហិរញ្ញវត្ថុ*

មូលនិធិបៃតងសម្រាប់បម្រែបម្រួលអាកាសធាតុ (GCF) ត្រូវបង្កើតឡើងជាយន្តការហិរញ្ញវត្ថុតាមមាត្រា ១១ នៃអនុសញ្ញា (UNFCCC)។ មូលនិធិនេះគាំទ្រគម្រោង កម្មវិធី គោលនយោបាយ និងសកម្មភាពរបស់ប្រទេសកំពុងអភិវឌ្ឍន៍តាមរយៈការផ្តល់ជំនួយឥតសំណង និងប្រាក់កម្ចីបែបសម្បទាន។ មូលនិធិនេះមានគណនេយ្យភាពចំពោះ និងប្រតិបត្តការក្រោមការតម្រង់ទិសរបស់ (COP)។ ១០.២ កោដដុល្លារអាមេរិកត្រូវបានសន្យានៅឆ្នាំ២០១៤។ នៅក្នុងក្របខ័ណ្ឌអនុសញ្ញា (UNFCCC) ប្រទេសអភិវឌ្ឍន៍បានបានសន្យាជាផ្លូវការថានឹងផ្តល់ប្រាក់មូលនិធិឲ្យបាន ១០០កោដ ក្នុង១ឆ្នាំ ចាប់ពីឆ្នាំ ២០២០។[14] មូលនិធិបៃតងនេះនឹងផ្តោតទៅលើទាំង វិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងវិធានការបន្សុំ និងធនាថាប្រទេសដែលប្រើប្រាស់មូលនិធិ ជាប្រទេសដៃគូ និងមានភាពជាម្ចាស់លើសកម្មភាព ឬគម្រោងដែលទទួលការគាំទ្រថវិកាពីមូលនិធិបៃតងនេះ។

មូលនិធិបៃតងនេះជាយន្តការហិរញ្ញវត្ថុថ្មីចុងក្រោយ ដែលរំពឹងថានឹងផ្តល់ជំនួយ ឬកម្ចី នៅឆ្នាំ២០១៥។ មូលនិធិបៃតងនេះ ក៏ជាយន្តការហិរញ្ញវត្ថុ ដែលបំពេញបន្ថែមទៅលើយន្តការហិរញ្ញវត្ថុដែលមានស្រាប់នៅក្រោម UNFCCC ដែលមិនបានបំពេញតម្រូវការគ្រប់គ្រាន់នៅឡើយ។[15] យន្តការហិរញ្ញវត្ថុបច្ចុប្បន្នរួមមាន៖ (១) ហិរញ្ញវត្ថុជាសាកល (២) មូលនិធិការប្រែប្រួលអាកាសធាតុពិសេស (៣) មូលនិធិសម្រាប់ប្រទេសមានការអភិវឌ្ឍន៍តិចតួច និង (៤) មូលនិធិបន្សុំ។

នៅសន្និសីទឆ្នាំ ២០១៤ (COP២០) នៅទីក្រុងលីម៉ា ប្រទេសចិនបានបដិសេធការធ្វើវិភាគទានទៅឲ្យមូលនិធិបៃតងសម្រាប់ការប្រែប្រួលអាកាសធាតុនេះ[16] និងមានគម្រោងបង្កើតមូលនិធិសហប្រតិបត្តិការ

---

[13]C2ES 2014. Outcomes of the UN Climate Change Conference in Lima. Accessed on August 20, 2015 at: http://www.c2es.org/international/negotiations/cop-20-lima/summary

[14]Green Climate Fund. Facts at a Glance. Accessed on September 1, 2015 at: http://news.gcfund.org/download/PDF/introducing-the-GCF.pdf

[15]UNFCC website. Fact sheet: Financing climate change action Investment and financial flows for a strengthened response to climate change. Accessed on September 01, 2015 at: http://unfccc.int/press/fact_sheets/items/4982.php

[16]C2ES 2014. Outcomes of the UN Climate Change Conference in Lima. Accessed on August 20, 2015 at: http://www.c2es.org/international/negotiations/cop-20-lima/summary

ត្បូង- ត្បូង សម្រាប់ការប្រែប្រួលអាកាសធាតុ (Climate Change South-South Cooperation Fund) និងធ្វើការជាមួយប្រទេសកំពុងអភិវឌ្ឍន៍។ ប្រទេសចិនក៏បានសន្យាថានឹងបង្កើនថវិកាទ្វេរដងសម្រាប់គម្រោងបង្កើតមូលនិធិសហប្រតិបត្តិការត្បូង-ត្បូងនេះ។

*៤. ការបាត់បង់ និងការខូចខាត*

សន្និសីទធាតុអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុឆ្នាំ ២០១៣ នៅទីក្រុង Warsaw បានបើកដំណើរការដើម្បីពិចារណាលើវិធានការ ក្នុងការជួយប្រទេសកំពុងអភិវឌ្ឍន៍ និងងាយរងគ្រោះ(ពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុដែលមិនអាចជៀសវាងបាន) ទៅលើកិច្ចខិតខំប្រឹងប្រែងទាំងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំ។ ទោះជាយ៉ាងនេះក្តី ប្រទេសទាំងអស់នេះ ពុំអាចបញ្ចូលបញ្ហាការបាត់បង់ និងការខូចខាត របស់ខ្លួនទៅក្នុងបញ្ជីបញ្ហាសម្រាប់ពិភាក្សារបស់សន្និសីទទីក្រុងប៉ារីស ឆ្នាំ២០១៥ ឡើយ។

*៥. ជំហរកម្ពុជា[17] (សេចក្តីថ្លែងការនៅ COP20)*

កម្ពុជាបានចាត់ទុកបញ្ហាប្រឈមនឹង ការប្រែប្រួលអាកាសធាតុជាបញ្ហាសំខាន់នៅក្នុងគោលនយោបាយអភិវឌ្ឍន៍របស់ខ្លួន ដែលមានគោលបំណងកសាងសង្គមដែលធន់នឹងការប្រែប្រួលអាកាសធាតុ បញ្ចេញកាបូនិចតិច និង គិតគូពីបញ្ហាបរិស្ថាន និង ចូលរួមចំណែកក្នុងយុទ្ធនាការប្រឆាំងនឹងការប្រែប្រួលអាកាសធាតុជាសកល។ ចំនែកកម្ពុជាទទូចឲ្យកិច្ចព្រមព្រៀងថ្មីនេះនឹងត្រូវបានធ្វើឡើងដោយផ្អែកលើគោលការណ៍របស់ UNFCCC ដែលធានាឲ្យមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ជាពិសេស ការចូលរួមចំណែក និងកិច្ចខិតខំប្រឹងប្រែងផ្សេងៗរបស់ប្រទេសមានការអភិវឌ្ឍន៍តិច (Least Developed Countries LDC) គួរតែជាការស្ម័គ្រចិត្ត និងមានការគាំទ្រពីប្រទេសអភិវឌ្ឍន៍ទៅលើ ការកសាងសមត្ថភាព ហិរញ្ញវត្ថុ និងការផ្ទេរមកឲ្យនូវបច្ចេកវិទ្យា។ ប្រទេសអភិវឌ្ឍន៍គួរធានាជំនួយហិរញ្ញវត្ថុ បន្ថែមថ្មីទៀត ដែលទៀងទាត់ពេលវេលា និង ងាយនឹងយកមកប្រើប្រាស់។

**សម្គាល់៖** ធនាគារពិភពលោកបានដាក់កម្ពុជាក្នុងបញ្ជីប្រទេសមានប្រាក់ចំណូលទាប និងចាត់ជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើន ដែលងាយទទួលរងផលប៉ះពាល់បំផុតពីការប្រែប្រួលអាកាសធាតុ ។[18]

---

[17]World Bank 2009. Convenient Solutions to an Inconvenient Truth: Ecosystem-based Approaches to Climate Change. Accessed on August 27, 2015 at: http://siteresources.worldbank.org/ENVIRONMENT/Resources/ESW_EcosystemBasedApp.pdf

[18]ASEAN Joint Statement on Climate Change 2014 delivered by HlaMaungThein, Deputy Director General, Ministry of Environmental Conservation and Forestry, the Republic of the Union of Myanmar on behalf of

*៦.ជំហររបស់អាស៊ានស្តីពីការគាំទ្ររបស់ប្រទេសអភិវឌ្ឍន៍*

ទាក់ទងនឹងការគាំទ្រពីប្រទេសអភិវឌ្ឍន៍ អាស៊ានបានជម្រុញ និង លើកទឹកចិត្តឲ្យប្រទេសអភិវឌ្ឍន៍បង្កើនការគាំទ្រលើ ការកសាងសមត្ថភាព បច្ចេកទេស ការផ្ទេរបច្ចេកវិទ្យា និងហិរញ្ញប្បទានទៅឲ្យប្រទេសអភិវឌ្ឍន៍តិចបំផុត និងប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីសម្រេចឲ្យបានគោលបំណងនៃការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ បន្ថែមលើនេះទៀត ការព្រមព្រៀងគ្នា និងការដាក់ឲ្យដំណើរការ ការគាំទ្រដែលសន្យាដោយប្រទេសអភិវឌ្ឍន៍ គឺជាការងារបន្ទាន់ សម្រាប់ប្រទេសមានការអភិវឌ្ឍន៍តិចបំផុត។[19]

*៧. គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឬ របៀបវារៈឆ្នាំ ២០៣០*

នៅថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៥ មហាសន្និបាតអង្គការសហប្រជាជាតិដែលមានប្រទេស ១៩៣ ចូលរួម បានអនុម័តលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឬ របៀបវារៈឆ្នាំ ២០៣០ នៅឯជំនួបកំពូលអង្គការសហប្រជាជាតិស្តីពីអភិវឌ្ឍន៍ប្រកបដោយចីរភាព។ របៀបវារៈឆ្នាំ ២០៣០ រៀបរៀងដោយក្រុមការងារពិគ្រោះយេបល់របស់អង្គការសហប្រជាជាតិ ដោយមានការពិគ្រោះយោបល់ជាមួយរដ្ឋជាសមាជិក និងមានគោលដៅបំបាត់ភាពក្រីក្រនៃគ្រប់រូបភាពទាំងអស់។[20]

របៀបវារៈឆ្នាំ ២០៣០ ក៏នឹងដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុផងដែរ។ គោលដៅទី១៣ នៃរបៀបវារៈឆ្នាំ ២០៣០ គឺចាត់វិធានការបន្ទាន់ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នឹងផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ គោលដៅទី ១៣ រំពឹងថានឹងបំពេញបន្ថែមដល់កិច្ចព្រមព្រៀងស្តីពីការប្រែប្រួលអាកាសធាតុ ដែលរដ្ឋភាគីនឹងអនុម័តនៅប៉ារីសនៅចុងឆ្នាំ ២០១៥ នេះ។[21] គោលដៅទី ១៣ ដក់ចេញសកម្មភាពនានាដូចខាងក្រោមនេះ៖

---

ASEAN member states at the Joint High Level Segment 20th Session of the Conferences of the Parties to UNFCCC in Lima Peru in 2014.

[19] Speech by the IPU president, Hon. Saber Chowdhury, Accessed on August 24, 2015 at: http://www.ipu.org/splz-e/cop20/shc.pdf

[20] UN News Center 2015. UN adopts new Global Goals, charting sustainable development for people and planet by 2030. Accessed on 07 October 7, 2015 at: http://www.un.org/apps/news/story.asp?NewsID=51968#.VhR2hPmqqko

[21] The Sustainable Development Goals of the Post-2015 Agenda: Comments on the OWG and SDSN Proposals. Accessed on October 05, 2015 at: https://www.die-gdi.de/uploads/media/DIE__Comments__on__SDG__proposals__150226_07.pdf

- ជាការពង្រឹងភាពធន់ និងសមត្ថភាពបន្សាំទៅនឹងមុខសញ្ញាគ្រោះថ្នាក់ និងគ្រោះមហន្តរាយដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុនៅគ្រប់ប្រទេស។
- បញ្ចូលវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងការរៀបចំផែនការថ្នាក់ជាតិ។
- លើកកម្ពស់សកម្មភាពអប់រំ ការយល់ដឹង សមត្ថភាពមនុស្ស និងស្ថាប័នលើវិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ វិធានការបន្សាំ ការកាត់បន្ថយការប៉ះពាល់ និងប្រព័ន្ធផ្ដល់ព្រមានជាមុន។

ក្រៅពីគោលដៅទី ១៣ របៀបវារៈឆ្នាំ ២០៣០ ក៏មានវិធានការផ្សេងទៀត ដែលឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ វិធានការទាំងនោះរួមមាន៖

- លើកកម្ពស់ភាពធន់នៃអ្នកក្រីក្រទៅនឹងការប្រែប្រួលអាកាសធាតុ (ចំណុចដៅ ១.៥) នៃគោលដៅ ១៖ បំបាត់ភាពក្រីក្រនៃគ្រប់រូបភាពទាំងអស់)។
- អនុវត្តបច្ចេកទេសកសិកម្មដែលធននឹងការប្រែប្រួលអាកាសធាតុ និង កសាងសមត្ថភាពបន្សាំ (ចំណុចដៅ ២.៤ នៃ គោលដៅ ២៖ លុបបំបាត់ភាពស្រេកឃ្លាន សម្រេចឲ្យបានសន្តិសុខស្បៀង និង អាហាររូបត្ថម្ភប្រសើរឡើង និងលើកកម្ពស់កសិកម្មដែលមាននិរន្តរភាព)។
- ធនាឲ្យបាននូវលទ្ធភាពទទួលបានទឹកស្អាតសម្រាប់មនុស្សគ្រប់រូប និងដោយស្មើរភាពគ្នា (ចំណុចដៅ ៦.១ នៃ គោលដៅ ៦៖ ធនាឲ្យបាននូវលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យសម្រាប់មនុស្សគ្រប់រូប)។
- កសាងហេដ្ឋារចនាសម្ព័ន្ធកសិកម្មដែលមានគុណភាព និរន្តរភាព និង ធន់នឹងការប្រែប្រួលអាកាសធាតុ (ចំណុចដៅ ៩.១ នៃគោលដៅ ៩៖ កសាងហេដ្ឋារចនាសម្ព័ន្ធកសិកម្មដែលធន់នឹង ការប្រែប្រួលអាកាសធាតុ និងលើកកម្ពស់ឧស្សាហូបនីយកម្ម ដែលមាននិរន្តរភាព និងការច្នៃប្រឌិត)។
- បង្កើនចំនួនទីក្រុង និងលំនៅដ្ឋាន ដែលជ្រើសយក និងអនុវត្តគោលនយោបាយ និងផែនការដែលឆ្ពោះទៅរកការរួមបញ្ចូល ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន វិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ វិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងភាពធន់ទៅនឹងគ្រោះមហន្តរាយ (ចំណុចដៅ ១១.b នៃ គោលដៅ ១១៖ ធ្វើឲ្យទីក្រុងមានភាពធន់ មានសុវត្ថិភាព និងមាននិរន្តរភាពសម្រាប់មនុស្សគ្រប់រូប)។
- គ្រប់គ្រង និងការពារប្រព័ន្ធអេកូឡូស៊ីសមុទ្រ និងឆ្នេរសមុទ្រ (ចំណុចដៅ ១៤.២ នៃគោលដៅ ១៤៖ អភិរក្ស និងប្រើប្រាស់ មហាសមុទ្រ សមុទ្រ និងធនធនធានសមុទ្រដោយមាននិរន្តរភាព)។

## មុខងាររបស់សភា និងការប្រែប្រួលអាកាសធាតុ

ទោះបីជា រដ្ឋាភិបាលជាអ្នកអនុវត្តគោលនយោបាយ កម្មវិធី និងសកម្មភាពផ្សេងៗជាច្រើនពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុក៏ដោយ សភាក៏មានភារៈកិច្ចរួមចំណែកក្នុងការដោះស្រាយបញ្ហាទាក់ទង់នឹងការប្រែប្រួលអាកាសធាតុនេះដែរ។ សភាអាចចូលរួមការងារពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ តាមរយៈមុខងារសំខាន់ៗចំនួនបី គឺ *ត្រួតពិនិត្យ នីតិកម្ម (ការបង្កើតច្បាប់) និងតំណាង*។[22]

*មុខងារត្រួតពិនិត្យ៖* ទោះបីថា រដ្ឋាភិបាលជាអ្នកអនុវត្តកម្មវិធី សកម្មភាពទាំងឡាយដែលឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុក៏ដោយ ក៏សភាអាចមានឥទ្ធិពលទៅលើលទ្ធផលដែលសម្រេចដោយរដ្ឋាភិបាល ហើយ សភាក៏អាចធ្វើការត្រួតពិនិត្យទៅលើថវិកា កម្មវិធីផ្សេងៗ និងការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលដែរ។[23]

*មុខងារនីតិកម្ម៖* សភាមានឥទ្ធិពលខ្លាំងចំពោះសកម្មភាពទាំងឡាយពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ តាមរយៈមុខងារចម្បងក្នុងការបង្កើតច្បាប់។ សភាអាចបញ្ចូលគោលនយោបាយទាក់ទងនឹងការប្រែប្រួលអាកាសធាតុ គោលនយោបាយអភិវឌ្ឍន៍ដែលមានភាពឆ្លាតវៃ គោលបំណង និងគោលដៅ នៅក្នុងច្បាប់។ ហើយសភាអាចអនុវត្តការងារនេះតាមរយៈការប្រឹក្សាយោបល់ជាមួយសហគមន៍ សាធារណៈជន និងដៃគូពាក់ព័ន្ធផ្សេងៗទៀតដែរ។[24]

*មុខងារតំណាង៖* សភាមានតួនាទីជួយដាស់តឿនប្រជាពលរដ្ឋ ដូចជាបញ្ហាពាក់ព័ន្ធនឹងផលប៉ះពាល់ការប្រែប្រួលអាកាសធាតុលើបរិស្ថាន ការអប់រំណែនាំសាធារណៈអំពីការខិតខំប្រឹងប្រែងដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។[25]

## សហភាពអន្តរសភា និងការប្រែប្រួលអាកាសធាតុ

ពាក់ព័ន្ធនឹងសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សហភាពអន្តរសភា (IPU) មានគោលបំណងប្រើអំណាចរដ្ឋធម្មនុញ្ញដែលមាននៅក្នុងស្ថាប័នសភាប្រទេសជាសមាជិក ដើម្បីជំរុញឲ្យមានឆន្ទៈនយោបាយ ដែលចាំបាច់សម្រាប់ការអភិវឌ្ឍន៍សង្គមដែលបញ្ចេញកាបោនតិច និងមានភាពធន់ទៅនឹង

---

[22]Parliament and climate change, Professional Development Program for Parliamentarians and Parliamentary Staff. Access on August 20, 2015 at: http://www.parliamentarystrengthening.org/climatechangemodule/

[23]Ibid

[24]Ibid

[25]The 2015 Global Climate Legislation Study. Foreword by the President of the Inter-Parliamentary Union. Accessed on September 2, 2015 at: http://www.lse.ac.uk/GranthamInstitute/publication/2015-global-climate-legislation-study/

ការប្រែប្រួលអាកាសធាតុ។[26] សហភាពអន្តរសភា (IPU) ជឿជាក់ថាសភាគឺតួអង្គដ៏សំខាន់ នៅក្នុងយុទ្ធសាស្ត្រ ដែលជោគជ័យក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ និងជឿជាក់ទៀតថាសភាក៏មានការទទួលខុសត្រូវមួយចំណែកលើការអនុវត្តន៍ផែនការយុទ្ធសាស្ត្រទាក់ទងនឹងការប្រែប្រួលអាកាសធាតុឲ្យមានប្រសិទ្ធភាព។ ជាងនេះទៀត សភាក៏មានកាតព្វកិច្ចក្នុងការអនុម័ត ការធ្វើវិសោធនកម្មច្បាប់ ការអនុម័តថវិកាជាតិ និងការតាមដានគ្រប់គ្រងសកម្មភាពរដ្ឋាភិបាលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែរ។[27]

សហភាពអន្តរសភា ដោយធ្វើការជិតស្និទ្ធជាមួយបណ្តាសភាជុំវិញពិភពលោក មានគោលបំណងបង្កើតផែនការសកម្មភាពសភា សម្រាប់វិធានការដ៏មានប្រសិទ្ធិភាពទៅលើការប្រែប្រួលអាកាសធាតុ បន្ទាប់ពីសន្និសីទទីក្រុងប៉ារីសឆ្នាំ២០១៥ រហូតដល់ឆ្នាំ២០២០។[28] បន្ទាប់ពីសន្និសីទ២០១៥ នេះ សភានៃប្រទេសនីមួយៗត្រូវសម្រេចដាក់បញ្ចូលកិច្ចព្រមព្រៀងថ្មីនេះទៅក្នុងច្បាប់ជាតិរបស់ខ្លួន រួមជាមួយការដើរតួនាទីទាំងបីខាងលើដើម្បីធានាការអនុវត្តន៍ប្រកបដោយប្រសិទ្ធិភាព។

លើសពីនេះទៀត សហភាពអន្តរសភា (IPU) រំពឹងថាសមាជិកសភា ឬ ព្រឹទ្ធសភាដែលចូលរួមមហាសន្និបាទ នឹងសិក្សា ផ្តល់យោបល់លើ និងអនុម័ត ឯកសារព្រាងនៃលទ្ធផលប្រជុំ (ដែលបានរៀបចំដោយ IPU) ដែលនឹងបញ្ជូនទៅ សន្និសីទអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុនៅចុងឆ្នាំ ២០១៥ នៅទីក្រុងប៉ារីស។ ឯកសារព្រាងនៃលទ្ធផលប្រជុំនេះ ទទួលស្គាល់ថាការប្រែប្រួលអាកាសធាតុកំពុងមានផលប៉ះពាល់ជាអវិជ្ជមាននៅជុំវិញពិភពលោក និងថាជាការកិច្ចការបន្ទាន់ក្នុងការកម្រិតការកើនកម្តៅឲ្យនៅក្រោម ២ អង្សាសេ។ ឯកសារព្រាងនៃលទ្ធផលប្រជុំនេះ បានរំលឹកពីគោលការណ៍របស់ UNFCCC ពោលគឺគោលការណ៍ «ការទទួលខុសត្រូវរួមគ្នា តែមានតួនាទីផ្សេងគ្នា»(Common but differentiated responsibilities) និងទៅតាមសមត្ថភាពរបស់រដ្ឋភាគីនិមួយៗ(respective capabilities) ហើយទទូចឲ្យកិច្ចព្រមព្រៀងនៅប៉ារីសថ្មីនេះគិតគូរអំពីការគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍន៍ដែលរួមមានហិរញ្ញវត្ថុ បច្ចេកវិជ្ជា និងការកសាងសមត្ថភាព។[29]

---

[26] Speech by the IPU president, Hon. Saber Chowdhury, Accessed on August 24, 2015 at: http://www.ipu.org/splz-e/cop20/shc.pdf

[27] The 2015 Global Climate Legislation Study. Foreword by the President of the Inter-Parliamentary Union. Accessed on September 2, 2015 at: http://www.lse.ac.uk/GranthamInstitute/publication/2015-global-climate-legislation-study/

[28] The 2015 Global Climate Legislation Study. Foreword by the President of the Inter-Parliamentary Union. Accessed on September 2, 2015 at: http://www.lse.ac.uk/GranthamInstitute/publication/2015-global-climate-legislation-study/

[29] IPU 2015. Preliminary draft outcome document of the Parliamentary meeting on the occasion of the UN Climate Change Conference. Accessed on October 05, 2015 at: http://www.ipu.org/conf-e/133/2cmt-4-dr1.pdf

ជាចុងក្រោយ ឯកសារព្រាងនៃលទ្ធផលប្រជុំ បានសន្យាថា ការសហការណ៍ រវាងសភាដែលជាសមាជិក សហភាពអន្តរសភា (IPU) នឹងជាមធ្យោបាយក្នុងការពង្រឹង សមត្ថភាពសភាក្នុងការអនុវត្ត និង តាមដានការអនុត្តច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ និងការចែករំលែកបទពិសោធន៍ល្អៗ។[30]

## អាស៊ាន និងការប្រែប្រួលអាកាសធាតុ

អាស៊ានបានបង្ហាញពីក្តីបារម្ភណ៍ និងការប្តេជ្ញាចិត្តក្នុងការចូលរួមដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ តាមរយៈសេចក្តីប្រកាស និងសេចក្តីថ្លែងការណ៍មួយចំនួននៅក្នុងសន្និសីទអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។[31] នៅក្នុងសេចក្តីថ្លែងការណ៍ក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី១៦ នៅឆ្នាំ២០១០ អាស៊ាន យល់ឃើញថាតំបន់អាស៊ីភាគអាគ្នេយ៍ គឺជាតំបន់ដែលងាយទទួលរងគ្រោះពីការប្រែប្រួលអាកាសធាតុ ហើយសេចក្តីថ្លែងការណ៍នោះដែរក៏បានបញ្ជាក់សារជាថ្មីពីការប្តេជ្ញាចិត្តក្នុងការសម្រេចគោលដៅរបស់អនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុក្នុងក្របខ័ណ្ឌសហប្រជាជាតិ (United Nations Framework Convention on Climate Change)។[32]

អាស៊ានមានគោលនយោបាយ និងកម្មវិធីសកម្មភាពរបស់ខ្លួន ទាក់ទងនឹងបញ្ហាការប្រែប្រួលអាកាសធាតុ។ នៅក្នុងផ្នែក D នៃឯកសារផែនការសហគមន៍ សង្គមវប្បធម៌របស់អាស៊ាន (ASEAN Socio-Cultural Community Blueprint) បានបង្ហាញថា អាស៊ានមានគោលដៅពង្រឹងកិច្ចសហប្រតិបត្តិការទាំងថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ដើម្បីដោះស្រាយបញ្ហា និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ តាមរយៈបង្កើតឲ្យមាន សកម្មភាព យុទ្ធសាស្ត្រផ្សេងៗ។[33] សកម្មភាពយុទ្ធសាស្ត្រគន្លឹះមួយចំនួនដែលបានបញ្ចូលនៅក្នុងផែនការនេះរួមមាន៖

- លើកកម្ពស់ការយល់ដឹងជារួមរបស់បណ្តាប្រទេសអាស៊ានទៅលើការប្រែប្រួលអាកាសធាតុ
- ជម្រុញការខិតខំប្រឹងប្រែងក្នុងការបង្កើតគំនិតផ្តួចផ្តើមទាក់ទងទៅនឹងការប្រែប្រួលអាកាសធាតុនៅសម្រាប់អាស៊ាន
- ជម្រុញ ផ្សព្វផ្សាយ និងសម្របសម្រួលទៅលើការផ្លាស់ប្តូរចំនេះដឹង/ព័ត៌មាន ស្តីពីការអភិវឌ្ឍន៍ និងការស្រាវជ្រាវបែបវិទ្យាសាស្ត្រ(Research & Development: R&D) ការចែករំលែក និង

---

[30] Ibid

[31] Raman Letchumanan (?).Is there an ASEAN policy on climate change? Accessed on September 02, 2015 at: http://www.lse.ac.uk/IDEAS/publications/reports/pdf/SR004/ASEC.pdf

[32] ASEAN Leaders' Statement on Joint Response to Climate Change. Accessed on September 10, 2015 at: http://www.asean.org/news/item/asean-leaders-statement-on-joint-response-to-climate-change

[33] ASEAN 2009. ASEAN Socio-Cultural Community Blueprint.

ការផ្ទេរ បច្ចេកវិទ្យា និងការអនុវត្តន៍ល្អៗ ពាក់ព័ន្ធនឹងវិធានការណ៍ការបន្សាំ និងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់

- បង្កើតយុទ្ធសាស្ត្រថ្នាក់តំបន់ ដើម្បីពង្រឹងសមត្ថភាពបន្សាំ និងសេដ្ឋកិច្ចដែលបញ្ចេញកាបោនតិច (low carbon economy) និង
- ការជម្រុញយុទ្ធសាស្ត្រ ដើម្បីធានាថាគំនិតផ្តួចផ្តើមទាក់ទងនឹងបញ្ហាអាកាសធាតុនេះ នឹងធ្វើឲ្យសហគមន៍អាស៊ានមានភាពរីកចម្រើនផ្នែកសេដ្ឋកិច្ច ព្រមទាំងមានបរិស្ថានល្អផងដែរ។

ដើមប្បីអនុវត្តទៅតាមសេចក្តីថ្លែងការណ៍នៅកិច្ចប្រជុំកំពូលអាស៊ានលើកទី ១៦ ឆ្នាំ ២០១០ អាស៊ានបានអនុម័តផែនការសកម្មភាពអាស៊ានរួមស្តីពីការប្រែប្រួលអាកាសធាតុ (AAP-JRCC) ឆ្នាំ ២០១២។[34] ផែនការសកម្មភាពដែលបានបង្កើតឡើង ឆ្នាំ ២០១២ រួមមាន៖ (១) ការបន្សាំ (២) ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (៣) ហិរញ្ញវត្ថុ និងប្រើប្រាស់ថវិកា (៤) ការផ្ទេរបច្ចេកវិទ្យា (៥) ការកសាងសមត្ថភាព និង (៦) កិច្ចសហប្រតិបត្តិការតំបន់ផ្សេងៗទៀត។ គួរកត់សម្គាល់ផងដែរថា ផែនការសកម្មភាពរួមស្តីពីការប្រែប្រួលអាកាសធាតុ (AAP-JRCC) របស់អាស៊ានមិនមានការកំណត់គោលដៅ ដើម្បីឲ្យប្រទេសជាសមាជិកអាស៊ានអនុវត្តទេ ផ្ទុយទៅវិញ AAP-JRCC ផ្តោតទៅលើការចែករំលែកព័ត៌មាន បទពិសោធន៍ល្អៗ និងការរៀនសូត្រពីគ្នា។

ក្រុមការងារការប្រែប្រួលអាកាសធាតុអាស៊ាន (ASEAN Working Group on Climate Change: AWGCC) បានបង្កើតនៅឆ្នាំ ២០០៩ និងមានតួនាទីទទួលខុសត្រូវលើ ផែនការសកម្មភាពអាស៊ានរួមស្តីពីការប្រែប្រួលអាកាសធាតុ។[35] គំនិតផ្តួចផ្តើមស្តីពីការប្រែប្រួលអាកាសធាតុអាស៊ាន (ASEAN Climate Change Initiative: ACCI) គឺជាវេទិកាប្រឹក្សាយោបល់ ដើម្បីសម្របសម្រួល និងកិច្ចសហការរវាងអង្គភាពអាស៊ាន តាមវិស័យដែលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដូចជាថាមពល រុក្ខាប្រមាញ់ កសិកម្ម និង គ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីធានាឲ្យបាននូវ វិធីសាស្ត្រសម្របសម្រួលដ៏ល្អក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។[36]

ដោយមូលហេតុថាការប្រែប្រួលអាកាសធាតុជាបញ្ហាដែលពាក់ព័ន្ធនឹងវិស័យច្រើន មិនត្រឹមតែក្រុមការងារការប្រែប្រួលអាកាសធាតុអាស៊ាន (AWGCC) ទេដែលធ្វើការលើបញ្ហាការប្រែប្រួលអាកាសធាតុ មាន

[34] ASEAN Cooperation on Climate Change. Accessed on September 01, 2015 at: http://environment.asean.org/asean-working-group-on-climate-change/
[35] ASEAN Action Plan on Joint Response to Climate Change. Accessed on September 01, 2015 at: http://environment.asean.org/wp-content/uploads/2015/06/ANNEX-8-Lead-Countries-for-ASEAN-Action-Plan-on-Joint-Response-to-Climate-Change-27-March-2013.pdf
[36] Ibid

ក្រុមការងារផ្សេងៗទៀតដូចជា បរិស្ថាន កសិកម្ម និង រុក្ខាប្រមាញ់ ថាមពល និងដឹកជញ្ជូន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។[37]

ឧទាហរណ៍គម្រោងការប្រែប្រួលអាកាសធាតុអនុវត្តដោយអាស៊ានមានដូចតទៅ៖

- ខ្យល់បរិសុទ្ធក្នុងក្រុងតូចៗរបស់អាស៊ាន
- ការស្តារឡើងវិញ និង ការប្រើប្រាស់ដោយនិរន្តរភាពនូវតំបន់ព្រៃដីល្បាប់នៅតំបន់អាស៊ីអាគ្នេយ៍
- ការគ្រប់គ្រងប្រកបដោយនិរន្តរភាពនូវតំបន់ព្រៃដីល្បាប់នៅអាស៊ីអាគ្នេយ៍
- សកម្មភាពអាស៊ានស្តីពីការបំពុលឆ្លងដែន ដោយផ្សែង (ឧ .ផ្សែងបណ្តាលមកពីភ្លើងឆេះព្រៃ)
- និងកិច្ចសហប្រតិបត្តិការអាស៊ានស្តីពីទីក្រុងដែលមានបរិស្ថានស្អាត និងមាននិរន្តរភាព ។ល។

## សកម្មភាពកម្ពុជាឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

កម្ពុជាផ្តល់សច្ចាប័ន ដល់អនុសញ្ញា UNFCCC នឹងពិធីសារខ្យូតូ។ ដើម្បីបំពេញតួនាទីជារដ្ឋភាគី រាជរដ្ឋាភិបាលកម្ពុជាបានបំពេញការងារដូចខាងក្រោម៖

- ដាក់ជូនលេខាធិការដ្ឋាននៃ អនុសញ្ញា UNFCCC នូវផែនការទំនាក់ទំនងជាតិដំបូង (Cambodia´s Initial National Communication 2002) ឆ្នាំ ២០០២។ នេះជារបាយការណ៍ដែលផ្តល់ព័ត៌មានស្តីពី ឧស្ម័នផ្ទះកញ្ចក់(GHG) និង ជាវិធានការកាត់បន្ថយ និងមធ្យោបាយបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

- បានអនុម័ត និងដាក់ជូនលេខាធិការដ្ឋានអនុសញ្ញា UNFCCC នូវកម្មវិធីសកម្មភាពបន្សាំជាតិ (National Adaptation Program of Action: NAPA)។ តាមរយៈកម្មវិធីនេះ រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញថា កម្ពុជាគឺជាប្រទេសមានការអភិវឌ្ឍន៍តិចបំផុត និងជាប្រទេសកសិកម្ម ដែលងាយទទួលរងផលប៉ះពាល់ពីកាប្រែប្រួលអាកាសធាតុ។ ក្នុងន័យនេះ កម្មវិធីសកម្មភាពមានគោលបំណងផ្តល់ក្របខណ្ឌសម្រាប់ណែនាំ ដល់ការសម្របសម្រួលការ

---

[37]ASEAN Cooperation on Climate Change. Accessed on September 01, 2015 at: http://environment.asean.org/asean-working-group-on-climate-change/

អនុវត្តគំនិតផ្តួចផ្តើមការបន្សាំតាមរយៈការចូលរួមដើម្បីប្រមូលផ្តុំកម្លាំង ជាមួយនឹងកម្មវិធីជាច្រើនទៀតស្តីពីបរិស្ថាន និងការអភិវឌ្ឍ។[38]

- បានបង្កើត គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ឆ្នាំ២០០៦។ គណៈកម្មាធិការនេះ ជាយន្តការអន្តរក្រសួង និងមានតួនាទីបង្កើតយុទ្ធសាស្ត្រ គោលនយោបាយ ឧបករណ៍គតិយុទ្ធ កម្មវិធីពាក់ពន្ធ័នឹងបញ្ហាការប្រែប្រួលអាកាសធាតុ។ គណៈកម្មាធិការ នេះក៏ជំរុញឲ្យមានការដាក់បញ្ចូលបញ្ហាការប្រែប្រួលអាកាសធាតុ ទៅក្នុងយុទ្ធសាស្ត្រ គោលនយោបាយ ឧបករណ៍គតិយុទ្ធ ព្រមទាំងជម្រុញឲ្យមានការចូលរួមកាន់តែផុសផុល។[39]

- គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ជាមួយនឹងការចូលរួមពីក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល បានបង្កើតផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (Cambodia Climate Change Strategic Plan: CCCSP 2014-2023) ២០១៤ ដល់ ២០២៣។ ទស្សនវិស័យរបស់យុទ្ធសាស្ត្រនេះ គឺតម្រូវឲ្យកម្ពុជាជំរុញបង្កើតសង្គមបៃតង ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នកាបូនតិច ភាពធន់នឹងអាកាសធាតុ សមភាព និរន្តរភាព ហើយសង្គមបៃតងនេះត្រូវផ្អែកលើចំនេះដឹង។

ស្របជាមួយផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) ស្ថានប័ន និងក្រសួងពាក់ព័ន្ធចំនួន ១០[40] ក៏បានបង្កើតផែនការសកម្មភាព និងយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុតាម វិស័យដែរ។ ទាំងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពតាមវិស័យផ្សេងៗសុទ្ធតែធ្វើឡើងឲ្យស្របនឹង CCCSP និងដើម្បីសម្រេចគោលដៅ CCCSP។[41] ជាងនេះទៅទៀត ផែនការនេះក៏បានឆ្លុះបញ្ចាំងពី សារៈសំខាន់នៃការបញ្ជ្រាបបញ្ហាការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរកសាងផែនថ្នាក់ក្រោមជាតិដែរ។

---

[38]MoE 2006. National Adaptation Program of Action to Climate Change. Accessed on September 02, 2015 at: http://unfccc.int/resource/docs/napa/khm01.pdf

[39]RGC, Sub-Decree On The Establishment Of The National Climate Change Committee, Article 1(April 2006), 1. http://www.asianjudges.org/wp-content/uploads/2014/09/sub-decree-on-the-establishment-of-nccc-english.pdf

[40]The line ministries included: the Ministry of Environment (MoE); Ministry of Agriculture, Forestry and Fisheries (MAFF); Ministry of Industry, Mines and Energy (MIME); Ministry of Education, Youth and Sport (MoEYS); Ministry of Health (MoH); Ministry of Women's Affairs (MoWA); Ministry of Water Resources and Meteorology (MoWRAM); Ministry of Public Works and Transport (MPWT); Ministry of Rural Development (MRD); and the National Committee for Disaster Management (NCDM).

[41]NCCC 2013. Cambodia Climate Change Strategic Plan (2014-2023). Accessed on September 08, 2015 at: http://camclimate.org.kh/en/policies/nccc-news/197-cccsp-2014-2023-kh-en-final.html

បន្ថែមពីលើអ្វីដែលបានរៀបរាប់ខាងលើ នៅមានកម្មវិធីមានសារៈប្រយោជន៍ជាច្រើនទៀតដែលទាក់ទងនឹងវិធានការបន្សាំ និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។ កម្មវិធីទាំងនោះមានដូចខាងក្រោមៈ

- កម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុ បានបញ្ចប់នៅឆ្នាំ២០១៣ (Pilot Progam for Climate Resilience Project ended in 2013) មានគោលបំណងធានាថាការចំណាយផ្សេងៗទៅលើវិស័យកសិកម្ម ត្រូវផ្តោតជាសំខាន់ទៅលើផលវិជ្ជមាន និងអវិជ្ជមានដែលបណ្តាលពីការប្រែប្រួលអាកាសធាតុ។[42]

- សម្ព័ន្ធភាពការប្រែប្រួលអាកាសធាតុកម្ពុជា ដែលកំពុងស្ថិតក្នុងដំណើរការ (ongoing Cambodia Climate Change Alliance) គឺជាគម្រោងដែលបានទទួលមូលនិធិសម្រាប់ការគាំទ្រសម្រាប់ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

- កម្មវិធីបន្សាំនៅសហគមន៍នៅកម្ពុជា បានបញ្ចប់ឆ្នាំ ២០១៥ (Cambodia Communities Based Adaptation Program ended in 2015) គឺជាកម្មវិធីដែលទទួលជំនួយសម្រាប់ការបង្កើនភាពធន់របស់សហគមន៍ជនបទទៅនឹងការបម្រែបម្រួលអាកាសធាតុ។[43]

- កម្មវិធី UN-REDD+ (កាត់បន្ថយការបំភាយឧស្ម័នដោយការមិនកាប់បំផ្លាញព្រៃឈើ) (កំពុងដំណើរការបច្ចុប្បន្ន) រំពឹងថាការកាប់ព្រៃឈើនឹងអាចថយចុះ ពង្រឹងការអភិរក្ស និងលើកកម្ពស់ការគ្រប់គ្រងព្រៃដោយមាននិរន្តរភាព សម្រាប់ប្រយោជន៍ប្រជាពលរដ្ឋជាពិសេសគឺជនក្រីក្រតាមជនបទ សត្វព្រៃ និងអាកាសធាតុ។[44]

- គម្រោងលើកកម្ពស់ ការគ្រប់គ្រងទឹកឲ្យមានភាពធន់នឹងអាកាសធាតុ និង កម្មវិធីការអនុវត្តក្នុងវិស័យកសិកម្មនៅតាមទីជនបទ (កំពុងដំណើរការ) ( ongoing project for Promoting Climate Resilliant Water Management and Agricultural Practices in Rural Cambodia) មានកម្មវត្ថុជួយឲ្យវិស័យកសិកម្ម មិនសូវ ទទួលផលប៉ះពាល់ ពីការប្រែប្រួលនៃធនធានទឹកដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។[45]

---

[42]Preparation of a Strategic Pilot Program for Climate Resilience Project – Phase I. About us. Accessed on September 12, 2015 at: https://ppcrcambodia.wordpress.com/2012/04/20/about-us/
[43]UNDP Cambodia website. Environment and Energy. Accessed on September 09, 2015 at: http://www.kh.undp.org/content/cambodia/en/home/operations/projects/environment_and_energy.html
[44]UNDP Cambodia website. Environment and Energy. Accessed on September 09, 2015 at: http://www.kh.undp.org/content/cambodia/en/home/operations/projects/environment_and_energy.html
[45]Ibid.

- គម្រោងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពបានបញ្ចប់នៅខែកុម្ភៈ២០១៥ (Sustanable Forest Management Project ended in February 2015) មានគោលបំណង ពង្រឹងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព តាមរយៈការបញ្ចូលការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពសម្រាប់ព្រៃសហគមន៍ និងតំបន់ដែលមានការពារដោយសហគមន៍ ទៅក្នុងគោលនយោបាយ ការធ្វើផែនការ និងការអនុវត្ត។[46]

គម្រោងដូចបានរៀបរាប់ខាងលើ គឺគ្រាន់តែជាគម្រោងមួយចំនួនដែលដកស្រង់ចេញពីគេហទំព័ររបស់នាយកដ្ឋានការប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) នៅកម្ពុជាប៉ុណ្ណោះ។ មានគម្រោងដ៏ទៃទៀត ដែលនឹងអនុវត្ត ដោយក្រសួងពាក់ព័ន្ធចំនួន ១០ ខាងលើ ដែលបានរៀបចំផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាពរួចហើយ។

[46]UNDP Cambodia website. Environment and Energy. Accessed on September 09, 2015 at: http://www.kh.undp.org/content/cambodia/en/home/operations/projects/environment_and_energy.html

# ឯកសារយោង

ACT 2015. Getting Specific on the 2015 Climate Change Agreement: Suggestions for the Legal Text with Explanatory Memorandum. Accessed on August 21, 2015 at: http://www.wri.org/sites/default/files/uploads/ACT2015_LegalSuggestions.pdf

ASEAN 2009. ASEAN Socio-Cultural Community Blueprint.

ASEAN Action Plan on Joint Response to Climate Change. Accessed on September 01, 2015 at: http://environment.asean.org/wp-content/uploads/2015/06/ANNEX-8-Lead-Countries-for-ASEAN-Action-Plan-on-Joint-Response-to-Climate-Change-27-March-2013.pdf

ASEAN Cooperation on Climate Change. Accessed on September 01, 2015 at: http://environment.asean.org/asean-working-group-on-climate-change/

ASEAN Cooperation on Climate Change. Accessed on September 01, 2015 at: http://environment.asean.org/asean-working-group-on-climate-change/

ASEAN Leaders' Statement on Joint Response to Climate Change. Accessed on September 10, 2015 at: http://www.asean.org/news/item/asean-leaders-statement-on-joint-response-to-climate-change

C2ES 2014. Outcomes of the UN Climate Change Conference in Lima. Accessed on August 20, 2015 at: http://www.c2es.org/international/negotiations/cop-20-lima/summary

C2ES 2014. Outcomes of the UN Climate Change Conference in Lima. Accessed on August 20, 2015 at: http://www.c2es.org/international/negotiations/cop-20-lima/summary

Green Climate Fund. Facts at a Glance. Accessed on September 1, 2015 at: http://news.gcfund.org/download/PDF/introducing-the-GCF.pdf

MoE 2006. National Adaptation Program of Action to Climate Change. Accessed on September 02, 2015 at: http://unfccc.int/resource/docs/napa/khm01.pdf

NCCC 2013. Cambodia Climate Change Strategic Plan (2014-2023). Accessed on September 08, 2015 at: http://camclimate.org.kh/en/policies/nccc-news/197-cccsp-2014-2023-kh-en-final.html

Parliament and climate change, Professional Development Program for Parliamentarians and Parliamentary Staff. Access on August 20, 2015 at: http://www.parliamentarystrengthening.org/climatechangemodule/

Preparation of a Strategic Pilot Program for Climate Resilience Project – Phase I. About us. Accessed on September 12, 2015 at: https://ppcrcambodia.wordpress.com/2012/04/20/about-us/

Raman Letchumanan (?).Is there an ASEAN policy on climate change? Accessed on September 02, 2015 at: http://www.lse.ac.uk/IDEAS/publications/reports/pdf/SR004/ASEC.pdf

RGC, Sub-Decree On The Establishment Of The National Climate Change Committee, Article 1(April 2006), 1. http://www.asianjudges.org/wp-content/uploads/2014/09/sub-decree-on-the-establishment-of-nccc-english.pdf

Speech by the IPU president, Hon. Saber Chowdhury, Accessed on August 24, 2015 at: http://www.ipu.org/splz-e/cop20/shc.pdf

Speech by the IPU president, Hon. Saber Chowdhury, Accessed on August 24, 2015 at: http://www.ipu.org/splz-e/cop20/shc.pdf

The 2015 Global Climate Legislation Study. Foreword by the President of the Inter-Parliamentary Union. Accessed on September 2, 2015 at: http://www.lse.ac.uk/GranthamInstitute/publication/2015-global-climate-legislation-study/

The 2015 Global Climate Legislation Study. Foreword by the President of the Inter-Parliamentary Union. Accessed on September 2, 2015 at: http://www.lse.ac.uk/GranthamInstitute/publication/2015-global-climate-legislation-study/

UNFCCC website. http://unfccc.int/2860.php

UNDP Cambodia website. Environment and Energy. Accessed on September 09, 2015 at: http://www.kh.undp.org/content/cambodia/en/home/operations/projects/environment_and_energy.html

What is COP21/CMP11? Paris 2015. Accessed on August 25, 2015 at: http://www.cop21.gouv.fr/en/cop21-cmp11/what-cop21-cmp11

World Bank 2009. Convenient Solutions to an Inconvenient Truth: Ecosystem-based Approaches to Climate Change. Accessed on August 27, 2015 at: http://siteresources.worldbank.org/ENVIRONMENT/Resources/ESW_EcosystemBasedApp.pdf